ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ: ១៤០២ សហវ.ប្រក.

រាជធានីភ្នំពេញ, ថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ២០០៦

# ប្រកាស
## ស្តីពី
## ការដាក់ឱ្យអនុវត្តចំណាត់ថ្នាក់សេដ្ឋកិច្ចនៃមាតិកាថវិកាចំណាយរបស់រដ្ឋ

## ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ , ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៤ ដែលប្រកាសឱ្យប្រើច្បាប់ធម្មនុញ្ញបន្ថែម សំដៅធានានូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ , ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ , ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ , ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ ០១/នស/៩៣, ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុ ដែលត្រូវបានកែប្រែដោយច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ ១៩៩៥ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ ១០/នស/៩៤, ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ១៩៩៤ និង ត្រូវបានកែប្រែដោយច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ ២០០០ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/១២៩៩/១៥, ចុះថ្ងៃ ទី ២៥ ខែ ធ្នូ ឆ្នាំ ១៩៩៩ ត្រូវបានកែប្រែដោយច្បាប់ស្តីពីវិសោធនកម្មមាត្រា ២៦ នៃច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/ រកម/១២០២/០២០, ចុះថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ ២០០២ និង ត្រូវបានកែប្រែដោយច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ ២០០៧ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/១២០៦/០៣៥, ចុះថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ២០០៦
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០៦/០៣៥ , ចុះថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ២០០៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ ២០០៧
- បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក , ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៧៨ អនក្រ.បក , ចុះថ្ងៃទី ១៨ ខែ វិច្ឆិកា ឆ្នាំ ២០០៤ ស្តីពីការបំពេញមុខងារ និង[illegible] នាយកដ្ឋានមួយចំនួននៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- តាមការចាំបាច់របស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom , Khan Daun Penh, Phnom Penh, CAMBODIA.
ទូរស័ព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone : 855-23-724 664 Fax : 855-23-427 798

## សម្រេច

**ប្រការ ១ :** ត្រូវបានដាក់ឱ្យអនុវត្តចំណាត់ថ្នាក់សេដ្ឋកិច្ចនៃមាតិកាថវិកាទូទៅរបស់រដ្ឋ ដែលចែកជាចំណាត់ថ្នាក់ចំណូល និង ចំណាត់ថ្នាក់ចំណាយ និងដែលបានអនុញ្ញាតដោយច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ ២០០៧ ។ ចំណាត់ថ្នាក់ចំណូល និង ចំណាត់ថ្នាក់ចំណាយនេះ ត្រូវបានបែងចែកជា ក្រុម ប្រភេទ ជំពូក គណនី និង អនុគណនី ដូចមានចែងក្នុងឧបសម្ព័ន្ធទី ១ និង ឧបសម្ព័ន្ធទី ២ ភ្ជាប់ជាមួយនឹងប្រកាសនេះ ។

**ប្រការ ២ :** បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងប្រកាសនេះត្រូវទុកជានិរាករណ៍ ។

**ប្រការ ៣ :** ប្រកាសនេះចូលជាធរមាន ចាប់ពីថ្ងៃ ០១ ខែ មករា ឆ្នាំ ២០០៧ តទៅ ។

ឧបនាយករដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

គាត ឈន់

**ចំលងជូន**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ទីស្តីការគណៈរដ្ឋមន្ត្រី
  "ដើម្បីជ្រាបជាពត៌មាន"
- រាជកិច្ច
  "ដើម្បីផ្សព្វផ្សាយ"
- គ្រប់ក្រសួង - រដ្ឋលេខាធិការដ្ឋាន
- គ្រប់ខេត្ត ក្រុង
  "ដើម្បីអនុវត្ត"
- កាលប្បវត្តិ - ឯកសារ

# ឧបសម្ព័ន្ធ ១

# មាតិកាចំណូលថវិកាទូទៅរបស់រដ្ឋ

| ជំពូក | គណនី | អនុគណនី | ចំណាត់ថ្នាក់ចំណូល |
|---|---|---|---|
| សរុបរួមចំណូលថវិការបស់រដ្ឋ | | | |
| សរុបចំណូលប្រក្រតី | | | |
| ក្រុមទី១: ចំណូលពិត (ប្រភេទទី១+ប្រភេទទី២) | | | |
| ប្រភេទទី១: ចំណូលសារពើពន្ធ | | | |
| 70 | | | ចំណូលសារពើពន្ធក្នុងប្រទេស |
| | 700 | | ពន្ធលើផលទុន ប្រាក់ចំណេញ និង កំរៃទុន (រូបវ័ន្តបុគ្គល) |
| | | 7001 | ពន្ធលើប្រាក់បៀវត្ស |
| | | 7002 | ពន្ធលើផលទុននៃដីធ្លីផ្ទះសំបែង |
| | | 7003 | ពន្ធលើផលចំណេញពីការលក់អចលនទ្រព្យ |
| | 701 | | ពន្ធលើផលទុន ប្រាក់ចំណេញ និងកំរៃទុន (នីតិបុគ្គល) |
| | | 7011 | ពន្ធលើប្រាក់ចំណេញរបស់សហគ្រាសសាធារណ: |
| | | 7012 | ពន្ធលើប្រាក់ចំណេញសហគ្រាសឯកជន |
| | | 7013 | ពន្ធលើផលទុននៃដីធ្លីផ្ទះសំបែង |
| | | 7014 | ពន្ធលើផលចំណេញពីការលក់អចលនទ្រព្យ |
| | 702 | | ពន្ធទូទៅលើទ្រព្យសម្បត្តិ និង សេវា |
| | | 7021 | អាករលើផលរបរ-របបផ្ទៃក្នុង (សហគ្រាសសាធារណ:) |
| | | 7022 | អាករលើផលរបរ-របបផ្ទៃក្នុង (សហគ្រាសឯកជន) |
| | | 7023 | អាករលើតំលៃបន្ថែម-របបផ្ទៃក្នុង (សហគ្រាសសាធារណ:) |
| | | 7024 | អាករលើតំលៃបន្ថែម-របបផ្ទៃក្នុង (សហគ្រាសឯកជន) |
| | | 7025 | អាករលើតំលៃបន្ថែម-របបនាំចូល (សហគ្រាសប្រេងឥន្ធនៈ) |
| | | 7026 | អាករលើតំលៃបន្ថែម-របបនាំចូល (សហគ្រាសផ្សេងៗទៀត) |
| | 703 | | ពន្ធលើទ្រព្យសម្បត្តិបានកំណត់ |
| | | 7031 | អាករពិសេសលើទំនិញមួយចំនួន-របបផ្ទៃក្នុង |

# ឧបសម្ព័ន្ធ ១

## មាតិកាចំណូលថវិកាចរន្តរបស់រដ្ឋ

| ជំពូក | គណនី | អនុគណនី | ចំណាត់ថ្នាក់ចំណូល |
|---|---|---|---|
| | | 7032 | អាករពិសេសលើទំនិញមួយចំនួន-របបនាំចូល (សហគ្រាសប្រេងឥន្ធនៈ) |
| | | 7033 | អាករពិសេសលើទំនិញមួយចំនួន-របបនាំចូល (សហគ្រាសផ្សេងៗទៀត) |
| | 704 | | អាករលើសេវាដែលបានកំណត់ |
| | | 7041 | អាករលើកាស៊ីណូ |
| | | 7042 | អាករលើឆ្នោត |
| | | 7043 | អាករលើល្បែងភ្នាល់ផ្សេងៗ |
| | | 7044 | អាករអាកាសយានដ្ឋាន |
| | | 7048 | អាករពិសេសលើសេវាមួយចំនួនផ្សេងៗទៀត |
| | 705 | | អាករលើការប្រើប្រាស់ទ្រព្យសម្បត្តិ ឬ ការអនុវត្តន៍សកម្មភាព |
| | | 7051 | អាជ្ញាប័ណ្ណនាំចេញឈើ |
| | 708 | | ចំណូលសារពើពន្ធផ្សេងៗទៀត |
| | | 7081 | ពន្ធតែមប្រ៊ី |
| | | 7082 | ការផាកពិន័យ និង ទោសបញ្ញត្តិសារពើពន្ធ |
| **71** | | | **ចំណូលពន្ធលើពាណិជ្ជកម្មក្រៅប្រទេស** |
| | 710 | | ពន្ធ និង អាករលើការនាំចូល |
| | | 7101 | ពន្ធគយពីការនាំចូល |
| | | 7102 | កំរៃយកមុនពីការងារគយក្នុងការនាំចូល |
| | | | -កំរៃលើទំនិញនៃអាគារលក់ទំនិញរួចពន្ធ |
| | | | -កំរៃឆ្លងកាត់ |
| | | | -កំរៃផ្សេងៗលើការងារគយក្នុងការនាំចូល |
| | | 7103 | ពន្ធគយលើផលិតផលគេលសិលា |
| | | 7104 | អាករបន្ថែមលើផលិតផលគេលសិលាសំរាប់ថែទាំផ្លូវថ្នល់ |
| | | 7105 | ផលនៃការលក់ផ្តែកគយ |

# ឧបសម្ព័ន្ធ ១

# មាតិកាចំណូលថវិកាចរន្តរបស់រដ្ឋ

| ជំពូក | គណនី | អនុគណនី | ចំណាត់ថ្នាក់ចំណូល |
|---|---|---|---|
| | | 7106 | ពិន័យផ្សេងៗលើការនាំចូល |
| | 711 | | ពន្ធ និង អាករលើការនាំចេញ |
| | | 7111 | អាករលើការនាំចេញឈើ |
| | | 7112 | អាករលើការនាំចេញកៅស៊ូ |
| | | 7113 | អាករលើការនាំចេញផលិតផលកសិផលផ្សេងៗ |
| | | 7114 | កំរៃគ្រប់គ្រងការនាំចេញ |
| | | 7115 | ពិន័យផ្សេងៗលើការនាំចេញ |
| **ប្រភេទទី២ : ចំណូលមិនមែនសារពើពន្ធ** | | | |
| 72 | | | **ផលទុននៃទ្រព្យសម្បត្តិរដ្ឋ** |
| | 720 | | ផលនៃការជួលដីធ្លី |
| | | 7201 | សម្បទាននេសាទ |
| | | 7202 | សម្បទានព្រៃឈើ |
| | | 7203 | សម្បទានពីប្រេងកាត |
| | | 7204 | សម្បទានរ៉ែ |
| | | 7205 | ការជួលដីទំនេរ |
| | 721 | | ផលទុនពីសហគ្រាសសាធារណៈ |
| | | 7211 | ចំនួនលើសនៃទុនចល័ត |
| | | 7212 | ប្រាក់ចំណេញរបស់សហគ្រាសសាធារណៈ |
| | | 7213 | ការបង់ប្រាក់រំលស់ |
| 73 | | | **ផលទុនលើការលក់ ជួលទ្រព្យសម្បត្តិ និង សេវា** |
| | 730 | | សហគ្រាសសាធារណៈ រដ្ឋបាល និង សេវាដំណើរការ (រកចំណេញ) |
| | | 7301 | ផលទុនរបស់អាកាសចរស៊ីវិល |
| | | 7302 | ផលទុននៃសកម្មភាពភាពយន្ត |

# ឧបសម្ព័ន្ធ ១

## មាតិកាចំណូលថវិកាជាតិរបស់រដ្ឋ

| ជំពូក | គណនី | អនុគណនី | ចំណាត់ថ្នាក់ចំណូល |
|---|---|---|---|
| | | 7303 | ផលទុនពីសកម្មភាពទេសចរណ៍ |
| | | 7304 | ផលទុននៃសកម្មភាពវប្បធម៌ |
| | | 7305 | ផលទុនពីប្រៃសណីយ៍ និង ទូរគមនាគមន៍ |
| | | 7306 | ផលទុនពីវិទ្យុ និង ទូរទស្សន៍ |
| | | 7307 | ផលទុននៃរដ្ឋាករទឹក |
| | | 7308 | ផលទុនផ្សេងៗទៀត |
| | 731 | | រដ្ឋបាល និង សេវា (មិនរកចំណេញ) |
| | | 7311 | ការលក់សំភារៈបរិក្ខារ សំភារៈខូចខាត និង សំភារៈសិក្សា |
| | | 7312 | លក់ឯកសារ លតាប័ត្រ និង លិខិតបោះពុម្ពផ្សេងៗ |
| | | 7313 | ផលនៃការដឹកជញ្ជូនទំនិញ |
| | | 7314 | ផលនៃប្រតិបត្តិការអន្តរាគមន៍ដើម្បីថែទាំកិច្ចដំណើរការ |
| | | 7315 | កំរៃនៃការថែទាំ |
| | | 7316 | ផលបានពីការលក់ទ្រព្យសម្បត្តិកំទិចកំទីសត្វពាហនៈ |
| | 732 | | ផលពីការគ្រប់គ្រងរដ្ឋបាល |
| | | 7321 | អាករស្ថានទូត (ចំណូលពីលិខិតឆ្លងដែន និង ទិដ្ឋាការ) |
| | | 7322 | ផលពីការចុះបញ្ជីគណៈបក្សនយោបាយ |
| | | 7323 | ផលលើការបង្កើតសហគ្រាស |
| | | 7324 | ផលពីការបង់សិទ្ធប្រឡង |
| | | 7325 | ផលពីការលក់ស្លាកលេខ |
| | | 7326 | ចំណូលពីប្រដាប់ក្តី |
| | | 7327 | សេវាសុរិយោដី និង សេវាសំណង់ |
| | | 7328 | ផលពីការត្រួតពិនិត្យគុណភាពផលិតផល និង ការគោរពបទដ្ឋាន |
| | 733 | | ការជួលទ្រព្យសម្បត្តិអចល័ត |

# ឧបសម្ព័ន្ធ ១

# មាតិកាចំណូលថវិកាទូទៅរបស់រដ្ឋ

| ជំពូក | គណនី | អនុគណនី | ចំណាត់ថ្នាក់ចំណូល |
|---|---|---|---|
| | | 7331 | ការជួលសហគ្រាសសាធារណៈនៅថ្នាក់រដ្ឋបាលកណ្តាល |
| | | 7332 | ការជួលសហគ្រាសសាធារណៈនៅខេត្តក្រុង (មន្ទីរជំនាញ) |
| | | 7333 | ការជួលសំភារៈ និង មធ្យោបាយដឹកជញ្ជូន |
| | | 7334 | ការជួលអចលនវត្ថុ (អសង្ហារឹម) |
| | | 7335 | ចំណូលពីការប្រើប្រាស់សេវាបង្វែរដោយម្ចាស់កសិដ្ឋាន |
| **74** | | | **ផលពីការផាកពិន័យ និង ការដាក់ទណ្ឌកម្ម** |
| | 741 | | ផលពីការផាកពិន័យ និង ការដាក់ទណ្ឌកម្ម |
| **75** | | | **ការឧបត្ថម្ភ អំណោយ** |
| | 751 | | ឧបត្ថម្ភកធនផ្តល់ដោយរដ្ឋ (ក្រៅប្រទេស) |
| | | | ប្រទេស..... |
| | 752 | | ឧបត្ថម្ភកធនផ្តល់ដោយអង្គការអន្តរជាតិ |
| | 753 | | ជំនួយផ្សេងៗទៀត |
| **76** | | | **ផលហិរញ្ញវត្ថុ** |
| | 761 | | ការប្រាក់នៃការអោយខ្ចី |
| | 766 | | ចំណេញពីការប្តូរប្រាក់ |
| | 768 | | ផលហិរញ្ញវត្ថុផ្សេងទៀត |
| **77** | | | **ផលផ្សេងៗ និង ផលពិសេស** |
| | 771 | | ផលផ្សេងៗ និង កិច្ចប្រតិបត្តិការគ្រប់គ្រង |
| | | 7711 | ចំណូលពីការបង់អតិរេករបស់ថវិកាខេត្ត-ក្រុង |
| | | 7712 | កំរៃធនាគារ |
| | 772 | | ផលនៃឯកជនភាវូបនីយកម្មសហគ្រាសសាធារណៈ |
| | 775 | | ផលពីការលក់អចលនវត្ថុ (ការលក់ទ្រព្យសម្បត្តិរដ្ឋ) |
| | | | **ក្រុមទី២ : ចំណូលតាមដីកា** |

# ឧបសម្ព័ន្ធ ១

## មាតិកាចំណូលថវិកាទូទៅរបស់រដ្ឋ

| ជំពូក | គណនី | អនុគណនី | ចំណាត់ថ្នាក់ចំណូល |
|---|---|---|---|
| **ប្រភេទទី៣ : ចំណូលតាមដីកា (មិនឆ្លងកាត់សាច់ប្រាក់)** | | | |
| 78 | | | **ការងារនៃរដ្ឋទេយ្យ** |
| | | | **សរុបចំណូលខាងមូលធន** |
| | | | **ក្រុមទី១:ចំណូលពិត (ប្រភេទទី១+ប្រភេទទី២)** |
| **ប្រភេទទី១ : ចំណូលពីប្រភពផ្ទាល់** | | | |
| 27 | | | **អចលកម្មហិរញ្ញវត្ថុផ្សេងៗ** |
| | 271 | | ការអោយខ្ចី (ការសងវិញនូវមូលធន) |
| **ប្រភេទទី២ : ចំណូលពីប្រភពខាងពីក្រៅ** | | | |
| 13 | | | **ឧបត្ថម្ភកធនវិនិយោគ** |
| | 131 | | ឧបត្ថម្ភកធនទទួលសំភារៈបរិក្ខារ-ទ្វេភាគី |
| | | 1311 | ជប៉ុន |
| | | 1312 | បារាំង |
| | | 1313 | អាឡឺម៉ង់ |
| | | 1318 | ផ្សេងៗ |
| | 132 | | ឧបត្ថម្ភកធនទទួលសំភារៈបរិក្ខាពីអង្គការអន្តរជាតិ |
| | | 1321 | ធនាគារពិភពលោក |
| | | 1322 | ធនាគារអភិវឌ្ឍន៍អាស៊ី |
| | | 1323 | អង្គការអាហារពិភពលោក |
| | | 1324 | អង្គការអូប៉ិច |
| | | 1328 | ផ្សេងៗ |
| | 133 | | ឧបត្ថម្ភកធនសំរាប់ការរំលស់បំណុល |
| 16 | | | **ការខ្ចី និង បំណុលប្រហាក់ប្រហែល** |
| | 161 | | ការខ្ចីក្នុងប្រទេស |

# ឧបសម្ព័ន្ធ ១

# មាតិកាចំណូលថវិកាចរន្តរបស់រដ្ឋ

| ជំពូក | គណនី | អនុគណនី | ចំណាត់ថ្នាក់ចំណូល |
|---|---|---|---|
| | | 1611 | ធនាគារជាតិនៃកម្ពុជា |
| | | 1612 | ធនាគារពាណិជ្ជ |
| | | 1618 | ផ្សេងៗ |
| | 162 | | ការខ្ចីក្រៅប្រទេស |
| | | 1621 | ពហុភាគី |
| | | 1622 | ទ្វេភាគី |
| | | 1628 | ផ្សេងៗទៀត |
| | 165 | | បរិវិសករប័ណ្ណធនាគារ |
| | | 1651 | សន្និកប័ណ្ណ |
| | | 1652 | លើគណនីចរន្ត |
| | 166 | | សញ្ញាប័ណ្ណ |
| ក្រុមទី២ ចំណូលតាមជីកា | | | |
| ប្រភេទទី៣ : ចំណូលតាមជីកា (មិនឆ្លងកាត់សាច់ប្រាក់) | | | |

# ឧបសម្ព័ន្ធ ២

## មាតិកាចំណាយថវិកាជាតិរបស់រដ្ឋ

| ជំពូក | គណនី | អនុគណនី | ចំណាត់ថ្នាក់ចំណាយ |
|---|---|---|---|
| | | | **សរុបរួមចំណាយថវិកាជាតិរបស់រដ្ឋ** |
| | | | **សរុបចំណាយប្រក្រតី** |
| | | | **ក្រុមទី១ : ចំណាយពិត** |
| **ប្រភេទទី១ : មធ្យោបាយសេវា** | | | |
| **60** | | | **ការទិញ** |
| | 601 | | សំភារៈផ្គត់ផ្គង់ថែទាំ |
| | | 6011 | សំភារៈផ្គត់ផ្គង់ សំអាត និង អនាម័យ |
| | | 6012 | សំភារៈផ្គត់ផ្គង់ សំរាប់ថែទាំអាគារ |
| | | 6013 | សំភារៈផ្គត់ផ្គង់សំរាប់ថែទាំផ្លូវថ្នល់ ស្ពាន និង លូ |
| | | 6014 | សំភារៈផ្គត់ផ្គង់សំរាប់ថែទាំសំភារៈឧបករណ៍ |
| | | 6015 | ប្រេងឥន្ធនៈ និង ប្រេងរំអិល |
| | 602 | | សំភារៈផ្គត់ផ្គង់ផ្នែករដ្ឋបាល |
| | | 6021 | សំភារៈការិយាល័យ និង ការបោះពុម្ព |
| | | 6022 | សៀវភៅមើល និង ឯកសារ |
| | | 6028 | ផ្សេងៗ |
| | 603 | | ស្បៀងអាហារ និង ផលិតផលកសិកម្ម |
| | | 6031 | ស្បៀង |
| | | 6032 | ចំណីសត្វ |
| | | 6033 | ពូជ និង កូនរុក្ខជាតិ |
| | | 6034 | ផលិតផលការពារសុខមាលភាពរុក្ខជាតិ និង ជី |
| | | 6035 | ពូជសត្វ ឱសថ និង វត្ថុធាតុសំរាប់បសុពេទ្យ |
| | | 6038 | ផ្សេងៗ |
| | 604 | | សំលៀកបំពាក់ និង ការតុបតែង |

## ឧបសម្ព័ន្ធ ២

# មាតិកាចំណាយថវិកាចរន្តរបស់រដ្ឋ

| ជំពូក | គណនី | អនុគណនី | ចំណាត់ថ្នាក់ចំណាយ |
|---|---|---|---|
| | | 6041 | ឯកសណ្ឋាន |
| | | 6042 | សំលៀកបំពាក់ការពារសុវត្ថិភាព |
| | | 6043 | មេដាយ (គ្រឿងឥស្សរិយយស) |
| | | 6048 | ផ្សេងៗ |
| | 605 | | សំភារៈតូចតាច សង្ហារឹម និង សំភារៈបរិក្ខារ |
| | | 6051 | សំភារៈ និង បរិក្ខារ |
| | | 6052 | សង្ហារឹម |
| | | 6053 | សំភារៈប្រើប្រាស់ |
| | | 6058 | ផ្សេងៗ |
| | 606 | | ថាមពល និង ទឹក |
| | | 6061 | អគ្គិសនី |
| | | 6062 | ទឹក |
| | | 6068 | ផ្សេងៗ |
| | 607 | | សំភារៈ បរិក្ខារថែទាំសុខភាព |
| | 608 | | សំភារៈផ្គត់ផ្គង់ផ្សេងៗ |
| **61** | | | **សេវាខាងក្រៅ** |
| | 611 | | កិច្ចសន្យានៃការផ្តល់សេវាជាមួយសហគ្រាស |
| | 612 | | ការជួលមធ្យោបាយដឹកជញ្ជូន |
| | 613 | | ថ្លៃឈ្នួល និង បន្ទុក (អសង្ហារឹម) |
| | 614 | | សោហ៊ុយបណ្តុះបណ្តាលបុគ្គលិក |
| | 615 | | ការថែទាំ និង ជួសជុល |
| | | 6151 | ការថែទាំ ដីធ្លី ព្រៃឈើ និង តំបន់ឆ្នេរ |
| | | 6152 | ការថែទាំ ជួសជុលអាគារ និង ប្រាសាទ |

# ឧបសម្ព័ន្ធ ២

## មាតិកាចំណាយថវិកាទូទៅរបស់រដ្ឋ

| ជំពូក | គណនី | អនុគណនី | ចំណាត់ថ្នាក់ចំណាយ |
|---|---|---|---|
| | | 6153 | ការថែទាំ និង ជួសជុលផ្លូវ ថ្នល់ ស្ពាន និង លូ |
| | | 6154 | ការថែទាំបណ្តាញផ្សេងៗ |
| | | 6155 | ការថែទាំដែនទេសាទ |
| | | 6156 | ការថែទាំ និង ជួសជុលមធ្យោបាយដឹកជញ្ជូន |
| | | 6157 | ការថែទាំ និង ជួសជុលសំភារៈឧបករណ៍ការិយាល័យ សំភារៈព័ត៌មានវិទ្យា និង ទូរគមនាគមន៍ |
| | | 6158 | ការថែទាំ និង ជួសជុលសំភារៈឧបករណ៍បច្ចេកទេស |
| | 616 | | សោហ៊ុយធានារ៉ាប់រង |
| | 617 | | សោហ៊ុយសិក្សាពិសោធន៍ សោហ៊ុយនៃការប្រើប្រាស់សេវា និង សោហ៊ុយនៃការប្រើប្រាស់សិទ្ធិ |
| | | 6171 | សោហ៊ុយសិក្សាពិសោធន៍ |
| | | 6172 | សោហ៊ុយនៃការប្រើប្រាស់សេវា |
| | | 6173 | សោហ៊ុយនៃការប្រើប្រាស់សិទ្ធិ |
| | 618 | | សោហ៊ុយដឹកជញ្ជូន |
| | | 6181 | សំភារៈ និង ទំនិញ |
| 62 | | | **សេវាខាងក្រៅផ្សេងៗ** |
| | 621 | | បុគ្គលិកខាងក្រៅ |
| | | 6211 | ភ្នាក់ងារជាតិជាប់កិច្ចសន្យា |
| | | 6212 | ភ្នាក់ងារបរទេសជាប់កិច្ចសន្យា |
| | | 6213 | បុគ្គលិកសម្ងបភាពសាធារណៈផ្សេងៗ |
| | 622 | | ទំនាក់ទំនងសាធារណៈ និង ផ្សព្វផ្សាយ |
| | | 6221 | សោហ៊ុយទទួលភ្ញៀវជាតិ |
| | | 6222 | សោហ៊ុយទទួលភ្ញៀវបរទេស |
| | | 6223 | ប្រជុំ សិក្ខាសាលា និង សន្និសិទ្ធ |
| | | 6224 | សោហ៊ុយពិធីបុណ្យ |

# ឧបសម្ព័ន្ធ ២

## មាតិកាចំណាយថវិកាទូទៅរបស់រដ្ឋ

| ជំពូក | គណនី | អនុគណនី | ចំណាត់ថ្នាក់ចំណាយ |
|---|---|---|---|
| | | | . បុណ្យជាតិ និង បុណ្យប្រពៃណី |
| | | | . បុណ្យចំរើនព្រះជន្មាយុព្រះមហាក្សត្រ |
| | | | . បុណ្យរុក្ខទិវា |
| | | | . បុណ្យផ្សេងៗទៀត |
| | | 6225 | ចំណាយសំរាប់វត្ថុអនុស្សាវរីយ៍ក្នុង និង ក្រៅប្រទេស |
| | | 6226 | សោហ៊ុយសំរាប់ការតាំងពិព័ណ៌នៅក្នុង និង ក្រៅប្រទេស |
| | | 6227 | ការឃោសនា និង ផ្សព្វផ្សាយព័ត៌មានសាធារណៈ |
| | 623 | | សោហ៊ុយជាវសារព័ត៌មាន និង ឯកសារ |
| | 624 | | ចំណាយទូទាត់សោហ៊ុយក្នុងប្រទេស |
| | | 6241 | សោហ៊ុយដឹកជញ្ជូន |
| | | 6242 | សោហ៊ុយបេសកកម្ម |
| | | 6243 | សោហ៊ុយស្នាក់នៅ |
| | 625 | | ចំណាយទូទាត់សោហ៊ុយក្រៅប្រទេស |
| | | 6251 | សោហ៊ុយដឹកជញ្ជូន |
| | | 6252 | សោហ៊ុយបេសកកម្ម |
| | | 6253 | សោហ៊ុយស្នាក់នៅ |
| | 626 | | សោហ៊ុយទូរគមនាគមន៍ ទូរស័ព្ទតេឡិច និង ទូរសារប្រៃសណីយ៍ |
| | | 6261 | សោហ៊ុយប្រៃសណីយ៍ |
| | | 6262 | សោហ៊ុយទូរគមនាគមន៍ |
| | 627 | | សោហ៊ុយធនាគារ |
| | 628 | | សោហ៊ុយផ្សេងៗ |
| 64 | | | បន្ទុកបុគ្គលិក |
| | 641 | | លាភការ និង ប្រាក់បំណាច់នៃអំណាចសាធារណៈ |

# ឧបសម្ព័ន្ធ ២

# មាតិកាចំណាយថវិកាឆ្នៅរបស់រដ្ឋ

| ជំពូក | គណនី | អនុគណនី | ចំណាត់ថ្នាក់ចំណាយ |
|---|---|---|---|
| | | 6411 | ខុទ្ទកាល័យព្រះបរមរាជវាំង |
| | | 6412 | ប្រាក់បំណាច់ប្រធាន អនុប្រធាន និង សមាជិកសភាជាតិ |
| | | 6413 | ប្រាក់បំណាច់នាយករដ្ឋមន្ត្រី និង ឧបនាយករដ្ឋមន្ត្រី |
| | | 6414 | ប្រាក់បំណាច់រដ្ឋមន្ត្រី រដ្ឋលេខាធិការ និង អនុរដ្ឋលេខាធិការ |
| | | 6415 | ប្រាក់បំណាច់អគ្គទូត |
| | | 6416 | លាភការទីប្រឹក្សា |
| | | 6417 | លាភការបេសកជន |
| | | 6418 | លាភការអ្នកជំនួយការ |
| | | 6419 | ការសង និង ការបង្វិលវិញ |
| | 642 | | លាភការ និង ប្រាក់បំណាច់បុគ្គលិកក្របខ័ណ្ឌអចិន្ត្រៃយ៍ |
| | | 6421 | បៀវត្សមូលដ្ឋាន |
| | | | . ចំនួន |
| | | | . ប្រភេទ |
| | | | . ខុទ្ទកាល័យ |
| | | | . នាយកដ្ឋាន |
| | | 6422 | ប្រាក់បំណាច់មុខងារ |
| | | 6423 | ប្រាក់បំណាច់ម៉ោងបន្ថែម |
| | | 6424 | ប្រាក់កំរៃគរុកោសល្យ |
| | | 6425 | ប្រាក់បំប៉នជីវភាពពិសេស |
| | | 6426 | ប្រាក់បំណាច់តំបន់ |
| | | 6427 | ប្រាក់បំណាច់ទទួលខុសត្រូវ |
| | | 6428 | ប្រាក់បំណាច់ការងារធ្ងន់ និង ប៉ះពាល់សុខភាព |
| | | 6429 | ការសង និង ការបង្វិលវិញ |

# ឧបសម្ព័ន្ធ ២

# មាតិកាចំណាយថវិកាឆ្នូទៅរបស់រដ្ឋ

| ជំពូក | គណនី | អនុគណនី | ចំណាត់ថ្នាក់ចំណាយ |
|---|---|---|---|
| | 643 | | រង្វាន់ និង ប្រាក់បំណាច់ផ្សេងៗទៀត |
| | | 6431 | កន្សោមអាទិភាព |
| | | 6432 | ប្រាក់បំណាច់សំរាប់ប្រឡង-ប្រឡងប្រជែង |
| | | 6433 | រង្វាន់ |
| | | 6434 | ប្រាក់បំណាច់បុគ្គលិកក្រសួងផ្សេងៗ |
| | | 6435 | អាហារសំរាប់បុគ្គលិករដ្ឋ |
| | | 6438 | ផ្សេងៗ |
| | | 6439 | ការសង និង ការបង្វិលវិញ |
| | 644 | | លាភការ និង ប្រាក់បំណាច់បុគ្គលិកមិនមែនក្របខ័ណ្ឌ និង បុគ្គលិកអណ្តែត |
| | | 6441 | បៀវត្សមូលដ្ឋានបុគ្គលិកមិនមែនក្របខ័ណ្ឌ |
| | | 6442 | លាភការផ្សេងៗទៀតបុគ្គលិកមិនមែនក្របខ័ណ្ឌ |
| | | 6443 | បៀវត្សមូលដ្ឋានបុគ្គលិកអណ្តែត |
| | | 6444 | លាភការផ្សេងៗទៀតបុគ្គលិកអណ្តែត |
| | | 6449 | ការសង និង ការបង្វិលវិញ |
| | 645 | | ប្រាក់វិភាជន៍សង្គម |
| | | 6451 | ប្រាក់បំណាច់ជាលក្ខណៈគ្រួសារ |
| | | | . កូនមានអាយុតិចជាង១៥ ឆ្នាំ |
| | | | . កូនរៀនវិទ្យាល័យ អនុវិទ្យាល័យ |
| | | | . ប្រាក់បំណាច់អ្នកក្នុងបន្ទុក |
| | | 6452 | មន្ត្រីមានជំងឺ និង ឧបត្ថម្ភអ្នកសំរាលកូន |
| | | 6453 | មរណៈភាព |
| | | 6454 | ឧបត្ថម្ភនិវត្តជន |
| | | 6455 | ឧបត្ថម្ភដល់អ្នកសុំឈប់ពីការងារ |

# ឧបសម្ព័ន្ធ ២

# មាតិកាចំណាយថវិកាទូទៅរបស់រដ្ឋ

| ជំពូក | គណនី | អនុគណនី | ចំណាត់ថ្នាក់ចំណាយ |
|---|---|---|---|
| | | 6456 | គ្រោះថ្នាក់ក្នុងការងារ និង ទុព្វលភាព |
| | | 6457 | ឧបត្ថម្ភដល់កូនកំព្រារបស់មន្ត្រីរាជការ |
| | | 6458 | ផ្សេងៗ |
| | | 6459 | ការសង និង ការបង្វិលវិញ |
| **ប្រភេទទី២ : បន្ទុកហិរញ្ញវត្ថុ** | | | |
| 66 | | | **បន្ទុកហិរញ្ញវត្ថុ** |
| | 661 | | ការប្រាក់នៃបំណុលក្នុងប្រទេស |
| | | 6611 | ធនាគារជាតិ |
| | | 6612 | ធនាគារពាណិជ្ជ |
| | | 6613 | ប័ណ្ណរតនាគារ |
| | | 6614 | សញ្ញាប័ណ្ណ |
| | | 6618 | ផ្សេងៗ |
| | 662 | | ការប្រាក់នៃបំណុលក្រៅប្រទេស |
| | | 6621 | ពហុភាគី |
| | | 6622 | ទ្វេភាគី |
| | 666 | | ខាតពីការប្តូរប្រាក់ |
| | 668 | | បន្ទុកហិរញ្ញវត្ថុផ្សេងៗទៀត |
| **ប្រភេទទី៣ : អន្តរាគមន៍សាធារណៈ** | | | |
| 65 | | | **ឧបត្ថម្ភកធន និង ជំនួយសង្គម** |
| | 651 | | ឧបត្ថម្ភកធនដល់រដ្ឋបាលដែនដី |
| | | 6511 | ឧបត្ថម្ភកធនដល់ខេត្ត-ក្រុង |
| | | 6512 | ឧបត្ថម្ភកធនដល់ស្រុក |
| | | 6513 | ឧបត្ថម្ភកធនដល់ឃុំ-សង្កាត់ |

# ឧបសម្ព័ន្ធ ២

## មាតិកាចំណាយថវិកាទូទៅរបស់រដ្ឋ

| ជំពូក | គណនី | អនុគណនី | ចំណាត់ថ្នាក់ចំណាយ |
|---|---|---|---|
| | 652 | | ឧបត្ថម្ភកធនដល់អង្គការសាធារណៈ |
| | 653 | | ឧបត្ថម្ភកធនដល់គ្រឹះស្ថានសាធារណៈមានលក្ខណៈរដ្ឋបាល |
| | 654 | | ការចូលរួមក្នុងការអនុវត្តន៍គំរោង |
| | | 6541 | ចំណាយប្រក្រតីក្នុងការអនុវត្តន៍គំរោង |
| | | 6542 | ចំណាយជាមូលធនក្នុងការអនុវត្តន៍គំរោង |
| | | 6549 | និយ័តកម្មចំណាយវិនិយោគ |
| | 655 | | ឧបត្ថម្ភកធនដល់សហគ្រាសសាធារណៈ |
| | | 6551 | ឧបត្ថម្ភកធនដល់សហគ្រាសសាធារណៈមិនមានលក្ខណៈហិរញ្ញវត្ថុ |
| | | | • ឧបត្ថម្ភកធនទុនចល័ត |
| | | | • ឧបត្ថម្ភកធនបំពេញខាត |
| | | | • ឧបត្ថម្ភកធនផ្សេងៗជាប្រចាំអោយសហគ្រាស |
| | | | • ឧបត្ថម្ភកធនផ្សេងៗសំរាប់តុល្យភាព |
| | | 6552 | ឧបត្ថម្ភកធនដល់សហគ្រាសសាធារណៈមានលក្ខណៈហិរញ្ញវត្ថុ |
| | 656 | | វិភាគទានដល់អង្គការអន្តរជាតិនានា |
| | | 6561 | អង្គការសហប្រជាជាតិ |
| | | 6562 | ធនាគារពិភពលោក |
| | | 6563 | ធនាគារអភិវឌ្ឍន៍អាស៊ី |
| | | 6564 | សហព័ន្ធអន្តរជាតិខាងកីឡាផ្សេងៗ |
| | | 6565 | អង្គការអាស៊ាន |
| | | 6568 | អង្គការអន្តរជាតិផ្សេងៗទៀត |
| | 657 | | ជំនួយសង្គម និង ប្រាក់វិភាជន៍ |
| | | 6571 | ជំនួយដល់ប្រជាជនសំរាកពេទ្យ |
| | | 6572 | ឱសថ |

# ឧបសម្ព័ន្ធ ២

## មាតិកាចំណាយថវិកាទូទៅរបស់រដ្ឋ

| ជំពូក | គណនី | អនុគណនី | ចំណាត់ថ្នាក់ចំណាយ |
|---|---|---|---|
| | | 6573 | អាហារ និង សំភារៈ |
| | | 6574 | ជួយជនរងគ្រោះដោយគ្រោះធម្មជាតិ |
| | | 6575 | សៀវភៅបំរុងរដ្ឋ |
| | | 6576 | អាហារូបករណ៍សំរាប់ការសិក្សា និង ស្រាវជ្រាវក្នុងប្រទេស |
| | | 6577 | អាហារូបករណ៍សំរាប់ការសិក្សា និង ស្រាវជ្រាវក្រៅប្រទេស |
| | | 6578 | ផ្សេងៗ |
| | 658 | | ឧបត្ថម្ភដល់អង្គភាពដែលមានលក្ខណៈសង្គម និង វប្បធម៌ |
| | | 6581 | ឧបត្ថម្ភសហគមន៍ |
| | | 6582 | ឧបត្ថម្ភមណ្ឌលកុមារកំព្រា |
| | | 6583 | ឧបត្ថម្ភដំណើរលំហែ និង សិក្សា |
| | | 6584 | ឧបត្ថម្ភកាកបាទក្រហម |
| | | 6585 | ឧបត្ថម្ភសហគមន៍កីឡា និង វប្បធម៌ |
| | | 6586 | ឧបត្ថម្ភមណ្ឌលស្តារលទ្ធភាពពលកម្ម នីតិសម្បទា និង បណ្តុះបណ្តាលអភិវឌ្ឍន៍ |
| | | 6587 | ចំណាយសង្គមកិច្ចរបស់ព្រះមហាក្សត្រ |
| **ប្រភេទទី៤ : ចំណាយផ្សេងៗ** | | | |
| 63 | | | **ពន្ធ និង អាករ** |
| | 631 | | លតាប័ត្រ |
| | 709 | | ការសង និង ការបង្វិលវិញ |
| | | 7090 | លើគណនី ៧០០ |
| | | 7091 | លើគណនី ៧០១ |
| | | 7092 | លើគណនី ៧០២ |
| | | 7093 | លើគណនី ៧០៣ |
| | | 7094 | លើគណនី ៧០៤ |

# ឧបសម្ព័ន្ធ ២

# មាតិកាចំណាយថវិកាទូទៅរបស់រដ្ឋ

| ជំពូក | គណនី | អនុគណនី | ចំណាត់ថ្នាក់ចំណាយ |
|---|---|---|---|
| | | 7095 | លើគណនី ៧០៥ |
| | | 7098 | លើគណនី ៧០៨ |
| **ក្រុមទី២: ចំណាយតាមដីកា និង ចំណាយមិនបានគ្រោងទុក** | | | |
| **ប្រភេទទី៥ : ចំណាយតាមដីកា (មិនឆ្លងសាច់ប្រាក់)** | | | |
| 67 | | | **បន្ទុកពិសេស** |
| | 671 | | ឥណទេយ្យដែលទទួលស្គាល់តែទារមិនបាន |
| | 675 | | តំលៃគណនេយ្យនៃចំណែកសកម្មបានលក់ (តំលៃនៅសល់) |
| 68 | | | **ទាយជ្ជទានអោយដល់រំលស់អចលកម្ម** |
| | 681 | | ទាយជ្ជទានអោយដល់រំលស់អចលកម្មអរូបី |
| | 682 | | ទាយជ្ជទានអោយដល់រំលស់អចលកម្មរូបី |
| **ប្រភេទទី៦ : ចំណាយមិនបានគ្រោងទុក** | | | |
| 09 | | | **ចំណាយមិនបានគ្រោងទុក** |
| | 091 | | ចំណាយត្រៀមបំរុង |
| | 092 | | ចំណាយផ្សេងៗ |
| **សរុបចំណាយជាមូលធន** | | | |
| **ក្រុមទី១: ចំណាយពិត** | | | |
| **ប្រភេទទី១ : ការទូទាត់ប្រាក់ខ្ចី និង បំណុលប្រហាក់ប្រហែល** | | | |
| 16 | | | **ការទូទាត់ប្រាក់ខ្ចី និង បំណុលប្រហាក់ប្រហែល** |
| | 161 | | ការទូទាត់ប្រាក់ខ្ចីក្នុងប្រទេស |
| | | 1611 | ធនាគារជាតិនៃកម្ពុជា |
| | | 1612 | ធនាគារពាណិជ្ជ |
| | | 1618 | ផ្សេងៗ |
| | 162 | | ការទូទាត់ប្រាក់ខ្ចីក្រៅប្រទេស |

## ឧបសម្ព័ន្ធ ២

# មាតិកាចំណាយថវិកាទូទៅរបស់រដ្ឋ

| ជំពូក | គណនី | អនុគណនី | ចំណាត់ថ្នាក់ចំណាយ |
|---|---|---|---|
| | | 1621 | ពហុភាគី |
| | | 1622 | ទ្វេភាគី |
| | | 1628 | ផ្សេងៗ |
| | 165 | | បរិវិសករប័ណ្ណរតនាគារ |
| | | 1651 | សន្និកប័ណ្ណ |
| | | 1652 | គណនីចរន្ត |
| | 166 | | សញ្ញាប័ណ្ណ |
| **ប្រភេទទី២ : អចលកម្ម** | | | |
| 20 | | | **អចលកម្មអរូបី** |
| | 203 | | សោហ៊ុយសិក្សាស្រាវជ្រាវ និង អភិវឌ្ឍន៍ |
| | | 2031 | សោហ៊ុយសិក្សា |
| | | 2032 | សោហ៊ុយស្រាវជ្រាវ និង អភិវឌ្ឍន៍ |
| | 205 | | ប្រកាសនីយប័ត្រ អាជ្ញាប័ណ្ណ និង សិទ្ធិប្រហាក់ប្រហែល |
| | | 2051 | ប្រកាសនីយប័ត្រ |
| | | 2052 | អាជ្ញាប័ណ្ណ |
| | | 2053 | សិទ្ធិប្រហាក់ប្រហែល |
| 21 | | | **អចលកម្មរូបី** |
| | 211 | | ដីធ្លី និង ធនធានធម្មជាតិ |
| | | 2111 | ដីធ្លី |
| | | 2112 | ដីរ៉ែ |
| | | 2118 | សម្បត្តិធម្មជាតិផ្សេងៗ |
| | 212 | | ការរៀបចំកែលំអដីធ្លី ដីរ៉ែ និង សម្បត្តិធម្មជាតិផ្សេងៗ |
| | | 2121 | ការរៀបចំកែលំអដីធ្លី |

# ឧបសម្ព័ន្ធ ២

# មាតិកាចំណាយថវិកាទូទៅរបស់រដ្ឋ

| ជំពូក | គណនី | អនុគណនី | ចំណាត់ថ្នាក់ចំណាយ |
|---|---|---|---|
| | | 2122 | ការរៀបចំកែលំអដីរ៉ែ |
| | | 2128 | ការរៀបចំកែលំអសម្បត្តិធម្មជាតិផ្សេងៗ |
| | 213 | | សំណង់ |
| | | 2131 | អាគារ |
| | | 2132 | ការរៀបចំកែលំអរអាគារ |
| | | 2138 | សំណង់ផ្សេងៗ |
| | 214 | | ហេដ្ឋារចនាសម្ព័ន្ធ |
| | | 2141 | ផ្លូវថ្នល់ |
| | | 2142 | ធារាសាស្ត្រ |
| | | 2143 | អាយស្ម័យាន |
| | | 2144 | អាកាសយានដ្ឋាន |
| | | 2145 | ទូរគមនាគមន៍ |
| | | 2146 | អគ្គិសនី |
| | | 2148 | ផ្សេងៗ |
| | 215 | | ឋបនកម្មបច្ចេកទេស សំភារៈ និង ហត្ថូបករណ៍ |
| | | 2151 | ឋបនកម្មបច្ចេកទេស |
| | | 2152 | សំភារៈ |
| | | 2153 | គ្រឿងឧបករណ៍ ( ហត្ថូបករណ៍) |
| | 216 | | ស្នាដៃសិល្បៈ និង ការប្រមូល ( សន្សំ) |
| | 218 | | អចលកម្មរូបីផ្សេងទៀត |
| | | 2181 | សំភារៈឧបករណ៍ដឹកជញ្ជូន |
| | | 2182 | សំភារៈឧបករណ៍ការិយាល័យ |
| | | 2183 | សំភារៈព័ត៌មានវិទ្យា និង ទូរគមនាគមន៍ |

# ឧបសម្ព័ន្ធ ២

## មាតិកាចំណាយថវិកាទូទៅរបស់រដ្ឋ

| ជំពូក | គណនី | អនុគណនី | ចំណាត់ថ្នាក់ចំណាយ |
|---|---|---|---|
| | | 2184 | សង្ហារឹម |
| | | 2188 | ផ្សេងៗទៀត |
| **23** | | | **អចលកម្មកំពុងដំណើរការ** |
| | 238 | | ប្រាក់រំដោះលើការងារវិនិយោគ |
| | | 2381 | អចលកម្មរូបី |
| | | 2382 | អចលកម្មអរូបី |
| **26** | | | **ភាគកម្ម និង ឥណទេយ្យពាក់ព័ន្ធ** |
| | 261 | | មូលប័ត្រនៃភាគកម្ម |
| **27** | | | **អចលកម្មហិរញ្ញវត្ថុផ្សេងៗ** |
| | 271 | | ការអោយខ្ចី |
| | | | **ក្រុមទី២ : ចំណាយតាមបដិកា** |
| **ប្រភេទទី៣ : ចំណាយតាមបញ្ញា** | | | |
| | | | ...................................... |